មាត្រា ២ .- ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០០

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាបង្គាប់

ប្រមុខស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៩ អនក្រ.បក

### ស្តីពីវិសោធនកម្ម នៃអនុក្រឹត្យលេខ ០៧ អន.ក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រង់មាត្រា ១.២.៣ និង ៨ ពាក់ព័ន្ធទៅនឹងឯកសណ្ឋានកងទ័ពជើងគោក កងនាវាចរ កងអាកាសចរ ឯកសណ្ឋានត្រែធំព និង កងកិត្តិយស

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋានផ្លាកសញ្ញានិងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០០

### សំរេច

មាត្រា ១ .- ក្នុងមាត្រា១ថ្មីនៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រូវបានកែតម្រូវដូចខាងក្រោម ៖

ត្រូវបានរៀបចំឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទថ្មី ដូចខាងក្រោម ៖

<u>រូបភាព ម៉ូតនិងប្រភេទឯកសណ្ឋាន</u> :

ក-<u>ឯកសណ្ឋានថ្នាក់ឧត្តមសេនីយនិងនាយ</u> :

១-<u>ឯកសណ្ឋានធំលេខ១</u> : ( អាវកុដស )

-អាវកុដស កត្រង់ ខោពណ៌ក្រមៅ មានឆ្នូតក្រហមពីរ ។

-អាវកុដស កត្រង់ កាត់រាងអាវធំ គ្មានឆែកខ្នង ត្រូវផលិតកអាវដែលមានកំពស់ ៤ ស.ម ដោយប៉ាក់ភ្នីទេសឱនពណ៌មាសជុំវិញពេញតួកអាវនិងប៉ាក់ផ្កាភ្ញីរាងកន្ទុយកណ្ដុរព័ទ្ធជុំវិញមានទំហំ ០,៣ ស.ម ។ លើស្មាទាំងសង្ខាងមានប៉ូល ហោប៉ៅបួន(ហោប៉ៅពីរខាងលើដេរប៉ះ ចំកណ្ដាល មានចាប់ផ្នត់មួយ គំរបរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោមដេរបង្កប់ គំរបរាងចតុកោណកែង ) អាវដៃវែងកាត់ម៉ូតដៃបំពង់ លើថ្នេរដៃបត់ចុងដៃអាវមានប៉ាក់ភ្នីទេសឱនពណ៌មាស ប៉ាក់រាងស្លឹកពោធិ ហើយចុងស្លឹកពោធិនោះត្រូវដាក់អោយចំពីលើខ្នងដៃ ។ ទំហំប៉ាក់ចាប់ពីចុងដៃអាវរហូតដល់ចុងស្លឹកពោធិមានកំពស់ ៩ ស.ម ផ្នែកខាងក្រោយចុងដៃអាវត្រូវប៉ាក់មកលើកំពស់ ៥,៥ ស.ម ។ នៅជុំវិញភ្នីទេសឱនត្រូវប៉ាក់ផ្កាភ្ញីរាងកន្ទុយកណ្ដុរព័ទ្ធជុំវិញមានទំហំ ០,៣ ស.ម ឡេវអាវមានរូបព្រះសង្ហារពណ៌មាស ( ឡេវធំពីកអាវមកដល់ក្រោមចំនួន ៦ ឡេវហោប៉ៅចំនួន ៤ ឡេវប៉ូលស្មាទាំងសង្ខាង និងដាក់បញ្ឆោតនៅចុង ដៃអាវនីមួយៗពីរម្ខាង ) ។

-ខោជើងវែងចង្កេះត គ្មានភ្លី នៅខាងក្រោយមានហោប៉ៅមួយដេរបង្កប់គ្មានគំរប ហោប៉ៅពីរនៅចំហៀងដេរបង្កប់តាមថ្នេរខោទាំងសង្ខាង ពីចង្កេះដល់ចុងជើង ខោមានឆ្នូតពណ៌ក្រហមពីរ ឆ្នូតនីមួយៗមានទំហំ ២ ស.ម ឃ្លាត ពីគ្នាចម្ងាយ ០,៥ ស.ម ។

-មួកកាសស្កេត ពណ៌ក្រមៅ ក្រណាត់កាំម្ទី ជើងមួកពណ៌ក្រហម ហាមមួកធ្វើពីកៅស៊ូរឹងពណ៌ខ្មៅ នៅលើហាមមួកមានប៉ាក់ភ្នីទេសឱនពណ៌មាសដល់ជើងមួក វ័ណ្ឌខាងមុខនិងឡេវ (រូបព្រះសង្ហារ ) ពណ៌មាស ។

-ស្បែកជើងឃ្លុប ពណ៌ខ្មៅ ធ្វើអំពីស្បែក កខ្លី ។

-ស្រោមជើងពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

-ខ្សែរំយោល ពណ៌មាសវេញចូលគ្នារាងសំប៉ែត ខ្សែអមបីមានមូលបន្តោកពីរពណ៌មាស មានក្បាច់ផ្កាភ្ញី ។

-ខ្សែក្រវាត់ ពណ៌ត្រែអ៊ី ក្បាលខ្សែក្រវាត់ធ្វើអំពីលោហធាតុលាតពណ៌មាស ( ប្រើគ្រប់ឯកសណ្ឋានទាំងអស់ ) ។

-ចំពោះនារី អាវមានគំរូដូចបុរស តែកាត់រាងតាមដងខ្លួននារី សំពត់ហ៊្វៀបក្រោមជង្គង់ពណ៌ក្រមៅ មានឆ្នូតក្រហមសង្ខាងដូចគ្នា ។

២-<u>ឯកសណ្ឋានធំលេខ ២</u> : ( អាវភ្លឺ )

-ឯកសណ្ឋានធំលេខ ២នេះ ពណ៌ត្រែអ៊ី អាវសឺមីក្នុងពណ៌ត្រែអ៊ីខ្ចី ក្រវាត់កពណ៌ខ្មៅ ។

-អាវកាត់រាងអាវភ្លឺ មានឆែកខ្នងមួយ កបើកប៉ូលស្មាទាំងសង្ខាង មានហោប៉ៅបួន ( ហោប៉ៅពីរខាងលើដេរប៉ះ ចំកណ្ដាលមានចាប់ផ្នត់មួយ គំរបរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោមដេរបង្កប់មានគំរបរាងចតុកោណ

កែង ) ដៃអាវវែងកាត់រាងដៃបំពង់ ។ ឡេវអាវមានរូបព្រះសង្ហារ ឡេវធំបួន ឡេវលោហធាតុចៀបួន ឡេវ តូចប៉ុលស្មាពីរ និងឡេវបញ្ចោតនៅចុងដៃអាវម្ខាងបី ។

-ខោជើងវែង ពណ៌ត្រែអ៊ី ផ្នែរបង្កប់ ចង្កេះត គ្មានគ្លី មានហោប៉ៅបួន ( ហោប៉ៅពីរខាងក្រោយដេរបង្កប់ មានគំរបរាងស្លឹកពោធិ នៅចំហៀងពីរ ដេរបង្កប់តាមថ្នេរខោ ) ។

-មួកកាសស្កេត ពណ៌ត្រែអ៊ី ជើងមួកពណ៌ខ្មៅ ហាមមួកធ្វើអំពីជ័ររឹងពណ៌ខ្មៅ ម៉ែណ្ណនឹងឡេវមួក ( រូបព្រះសង្ហារ ) ពណ៌មាស លើហាមមួកមានប៉ាក់ក្បាច់ភ្ញីទេសឱនដល់ជើងមួកទាំងសង្ខាង ។

-អាវសឺមីក្នុង ពណ៌ត្រែអ៊ីខ្ចី កាត់ស្រុងវែងដាក់ក្នុងខោ មានហោប៉ៅមួយនៅខាងឆ្វេង គ្មានគំរប ដៃអាវកាត់ ផែកដាក់ឡេវបិទ ។

-ក្រវាត់ កពណ៌ខ្មៅ ស្រោមដៃ ពណ៌ស ។

-ស្បែកជើងយួប ពណ៌ខ្មៅ ធ្វើពីស្បែក កខ្ចី ។

-ខ្សែក្រវាត់ ពណ៌ត្រែអ៊ី ក្បាលខ្សែក្រវាត់លោហធាតុលោត ពណ៌មាស ។

-ចំពោះនារី អាវដូចខាងលើ តែជីបចង្កេះ និងកអាវ តាមរាងដងខ្លួន សំពត់ហ្សិបក្រោមជង្គង់ ។

៣-ឯកសណ្ឋានលេខ ៣ : ( សាលាការីយែន )

-ឯកសណ្ឋាននេះទាំងអាវនិងខោ ពណ៌ត្រែអ៊ី ហោប៉ៅបួន ។

-អាវដៃខ្លី កបើក ខាងក្រោយមានផែក និងមានប៉ានចង្កេះ ផ្នែកខាងមុខហោប៉ៅបួន ( ពីរខាងលើ និងពីរ ខាងក្រោម ហើយហោប៉ៅអាវនិងគំរបត្រូវដេររាងមូល ប៉ូលស្មាទាំងសង្ខាង ឡេវរូបព្រះសង្ហារ ពណ៌មាស ) ។

-ខោជើងវែង ពណ៌ត្រែអ៊ី ( កាត់ម៉ូតដូចឯកសណ្ឋានលេខ ២ ) ។

-មួក ស្បែកជើង និងស្រោមជើង ( ដូចឯកសណ្ឋានលេខ ២ ) ។

-ចំពោះនារី អាវដូចបុរស តែជីបចង្កេះតាមរាងនារី ហើយសំពត់ហ្សិបពណ៌ត្រែអ៊ី ក្រោមជង្គង់ ។

៤-<u>ឯកសណ្ឋានការងារ ( លេខ ៤ )</u> : គំរូឯកសណ្ឋាននេះមានតែមួយសំរាប់គឺ ៖

-ឯកសណ្ឋានការងារ អាវពណ៌ត្រែអ៊ី ដៃខ្លី ហើយខោពណ៌ត្រែអ៊ី ។

-អាវដៃខ្លី ពណ៌ត្រែអ៊ី កឱប ប៉ូលស្មាទាំងសង្ខាង កាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅពីរដេរប៉ះ ចំកណ្ដាល ដេរបត់ផ្នត់មួយ មានគំរបរាងស្លឹកពោធិ ឡេវធម្មតាពណ៌ត្រែអ៊ី ។

-ខោជើងវែង ( ដូចឯកសណ្ឋានលេខ ៣ ) ពណ៌ត្រែអ៊ី ។

-មួកបោណេ ពណ៌ត្រែអ៊ី នៅស្រទាប់មួកមានចំពណ៌មាសតាមបណ្ដោយទំហំ ៨ម.ម ។

-ខ្សែក្រវាត់ ពណ៌ត្រែអ៊ី ( ដូចខ្សែក្រវាត់ឯកសណ្ឋានលេខ ១ ) ។

-ចំពោះនារី អាវដូចបុរស ខោជើងវែង កាត់ដូចបុរស តែខុសចំពោះនារី ផែក ឡេវចំហៀងឬសំពត់ ហ្សិប ពណ៌ត្រែអ៊ី ក្រោមជង្គង់ ។

៥-ឯកសណ្ឋានប្រយុទ្ធ ៖

-តំរូងឯកសណ្ឋានប្រយុទ្ធ មានតែមួយសំរាប់ អាវដៃវែង ហោប៉ៅបួន ខោជើងវែង ហោប៉ៅប្រាំមួយ ជើងខោចងខ្សែ ឬដាក់ខ្សែយឺតរិតជើង ពណ៌គ្រែអ៊ី ជើងគោក (ទ័ពពិសេស ស៊ើបការ ទ័ពការពារព្រំដែន និងឆ័ត្រយោង ពណ៌កាំម៉ូផ្លា ) ដោយឡែកថ្នាក់ឧត្តមសេនីយ ជាអទិភាពជាក់ប៉ានទាំងអស់ ។

-អាវដៃវែង កបើក ថ្នេរឧប ហោប៉ៅបួន ដេរយោគមកក្រៅទាំងអស់ មានគំរបរាងចតុកោណកែង ឡេវទាំងអស់ដាក់បង្កប់ ពណ៌គ្រែអ៊ី ដៃអាវវែង កាត់ដៃបំពង់ មានក្រវាត់និងឡេវ លើស្មាមានប៉ូលពីរសង្ខាង ។

-ខោជើងវែង ថ្នេរឧប ហោប៉ៅក្រោយពីរ ដេរបង្កប់ មានគំរបរាងចតុកោណកែង នៅចំហៀងតាមថ្នេរខោដេរបង្កប់មាត់ហោប៉ៅបញ្ឆិត ប៉ាន់ជង្គង់ នៅសង្ខាងភ្លៅមានហោប៉ៅធំពីរ នៅជើងម្ខាងមួយ ផ្នែកខាងក្រៅហោប៉ៅដេរយោគមកក្រៅ នៅកណ្តាលហោប៉ៅមានបត់ផ្នត់ពីរជាន់ គំរបរាងចតុកោណកែង ដាក់ឡេវពីរ ជើងខោចងខ្សែឬខ្សែយឺត ។

-មួកដែកនិងមួកហ្សីកកីពណ៌គ្រែអ៊ី ( ទ័ពពិសេស ទ័ពការពារព្រំដែននិងឆ័ត្រយោង ពណ៌កាំម៉ូផ្លា ) ហើយមួកហ្សីកកី នៅលើហាមមួករបស់ឧត្តមសេនីយមានប៉ាក់ភ្ញីទេសឌិន ដូចមួកកាសស្កេតដែរ ។

-ស្បែកជើងស្បែក កវែង ពណ៌ខ្មៅ ។

-ស្រោមជើងពណ៌គ្រែអ៊ី ។

-កន្សែងរុំក ( ហ្វូឡា ) ពណ៌គ្រែអ៊ី ក្រណាត់នីឡុង ។

-ប៉េរ៉េពណ៌គ្រែអ៊ី ជើងគោក ទ័ពពិសេស ឆ័ត្រយោងពណ៌ក្រហម ។

ខ-ឯកសណ្ឋានថ្នាក់វរសេនីយ ៖

១-ឯកសណ្ឋានលេខ១ ៖ ដូចថ្នាក់ឧត្តមសេនីយដែរ តែមានចំណុចមួយចំនួនខុសគ្នាដូចខាងក្រោម ៖

-ប៉ាក់ភ្ញីទេសឌិននៅលើកអាវខាងចុងបិទឡេវទាំងសង្ខាង ខាងដើមត្រូវប៉ាក់ទំហំ ៣ ស.ម ហើយបញ្ឆិតទៅលើប្រវែង ៧ ស.ម ដោយគិតពីខាងដើមមក ។

-នៅចុងដៃអាវមានប៉ាក់ភ្ញីទេសឌិនដូចថ្នាក់ឧត្តមសេនីយដែរ តែទំហំតូចជាងថ្នាក់ឧត្តមសេនីយចំនួនពាក់កណ្តាល ។

-មួក នៅលើហាមមួក ក្បាច់ភ្ញីទេសឌិន នៅចុងហាមមួកទុកចន្លោះពីជើងមួកសង្ខាង ប្រវែង ៥ ស.ម ។

-ខ្សែរំយោលវេញចូលគ្នាបីខ្សែដៃ តែទំហំតូចជាងថ្នាក់ឧត្តមសេនីយ ។

-ខោជើងវែងពណ៌ក្រមៅ ថ្នាក់វរសេនីយមានឆ្នូតពីរ ឆ្នូតនីមួយៗទទឹង១ ស.ម ។

២-ឯកសណ្ឋានលេខ ២+៣ ៖ រូបភាព ម៉ូត ពណ៌ ដូចថ្នាក់ឧត្តមសេនីយ តែខុសគ្នានៅហាមមួក ក្បាច់ភ្ញីទេសឌិនទុកចន្លោះពីដើមមួកសង្ខាង ៥ ស.ម ។

៣-ឯកសណ្ឋានលេខ ៤ ( អាវការងារ ) ៖ ដូចថ្នាក់ឧត្តមសេនីយ តែខុសគ្នាមួកបោណេ នៅស្រទាប់មួកថ្នេរមានចំពណ៌ក្រហមទំហំ៥ស.ម ។

៤-ឯកសណ្ឋានប្រយុទ្ធ : ដូចឧត្តមសេនិយ តែខុសគ្នា មួកហ្សីកកី ក្បាច់ភ្នីទេសឱិននៅបាតមួក ទុកចន្លោះ៥ស.ម ពីជើងមួក ។

គ-ឯកសណ្ឋានថ្នាក់អនុសេនិយ :

១-ឯកសណ្ឋានលេខ១ : ដូចថ្នាក់ឧត្តមសេនិយដែរ តែមានចំណុចខុសគ្នាសំរាប់សំគាល់ថ្នាក់ដូចខាងក្រោម ៖

-ប៉ាក់ភ្នីទេសឱិននៅលើកអាវខាងចុងបិទឡេវទាំងសង្ខាង ខាងដើមត្រូវប៉ាក់កំពស់២ស.ម បញ្ឆិតរៀវស្តួចឡើងប្រវែង ៧ស.ម នៅថ្មេរចុងដៃអាវមានចំពណ៌មាសទំហំ ១ស.ម ។

-មួកកាសស្តេត នៅហោមគ្មានក្បាច់ភ្នីទេសឱិនទេ តែមានចំជាឆ្នូតពណ៌មាសនៅចុងបាត ប្រវែងទទឹងឆ្នូតចំនួន ៦ម.ម ។

-ខោជើងវែងពណ៌ក្រមៅ ឆ្នូតមានតែមួយ ប្រវែងទទឹងឆ្នូត ២ស.ម ។

២-ឯកសណ្ឋានលេខ ២+៣ : ដូចថ្នាក់ឧត្តមសេនិយដែរ តែខុសគ្នាមួកកាសស្តេត លើបាតមួកគ្មានក្បាច់ភ្នីទេសឱិនទេ មានចំឆ្នូតពណ៌មាសនៅបាតមួកដូចមួកកាសស្តេតឯកសណ្ឋានធំលេខ ១ដែរ ។

៣-ឯកសណ្ឋានការងារ : ដូចគ្នាឧត្តមសេនិយ តែមួកបោណេចំពណ៌ទឹកប្រាក់ ។

៤-ឯកសណ្ឋានប្រយុទ្ធ : ដូចថ្នាក់ឧត្តមសេនិយដែរ តែមួកហ្សីកកីនៅបាតមួកមានចំឆ្នូតដូចមួកកាសស្តេតដែរ ។

ឃ-ថ្នាក់នាយទាហានរងនិងពលទាហាន :

-ក្នុងលក្ខណៈដែលក្រសួងការពារជាតិនិងអគ្គមេបញ្ជាការពិនិត្យឃើញថា : ត្រូវបំពេញបេសកកម្មនៅក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ នាយទាហានរងនិងពលទាហានអាចមានឯកសណ្ឋានធំលេខ២ ឬលេខ៣ដែរ។ ចំពោះឯកសណ្ឋានទាំងនោះដូចថ្នាក់អនុសេនិយដែរ តែមួកកាសស្តេតគ្មានក្បាច់ភ្នីទេសឱិន ឬឆ្នូតអ្វីទាំងអស់ ។

-ចំពោះនាយទាហានរងនិងពលទាហាន មានគោលរបបតែឯកសណ្ឋានការងារនិងឯកសណ្ឋានប្រយុទ្ធតែប៉ុណ្ណោះ ។ ចំពោះឯកសណ្ឋានការងារនិងប្រយុទ្ធដូចគ្នាថ្នាក់អនុសេនិយដែរ តែមួកបោណេនិងហ្សីកកីគ្មានឆ្នូតអ្វីទាំងអស់ ។ ចំពោះឯកសណ្ឋានការងារនិងប្រយុទ្ធដូចគ្នាថ្នាក់អនុសេនិយដែរ តែមួកបោណេនិងហ្សីកកីគ្មានឆ្នូតអ្វីទាំងអស់ ។

**មាត្រា ២ ._** ក្នុងមាត្រា២ថ្មីនៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រូវបានកែតម្រូវដូចខាងក្រោម :

ត្រូវបានរៀបចំឯកសណ្ឋានកងនាវាចរភូមិន្ទ និងអាកាសចរភូមិន្ទ ដូចខាងក្រោម ៖

ក-ឯកសណ្ឋានកងនាវាចរភូមិន្ទ កម្ពុជា :

-ឯកសណ្ឋានកងនាវាចរភូមិន្ទកម្ពុជា គ្រប់ឯកសណ្ឋាននិងគ្រប់ថ្នាក់ នាយទាហាន នាយទាហានរងនិងពលទាហានដូចទ័ពជើងគោក ខុសគ្នាតែពណ៌ប៉ុណ្ណោះ ។ ពណ៌ឯកសណ្ឋានកំណត់ដូចខាងក្រោម៖

-ឯកសណ្ឋានលេខ ១ លេខ ២ លេខ ៣ និងលេខ ៤ ( អាវកុដស អាវវ៉ារី សាហារីយែន និង ការងារ ... ប៉ុប្រភេទ ស្បែកជើង និងស្រោមជើង ពណ៌សទាំងអស់ ។ ចំពោះអាវសឺមីក្នុងរបស់ឯកសណ្ឋានលេខ ២ ... តែមួយពណ៌សប៉ុណ្ណោះ ។ ដោយឡែកឯកសណ្ឋានការងារមាន ០២ សំរាប់ (០១សំរាប់ពណ៌ស) ខ្សែក្រវាត់ តួចពណ៌ស ក្បាលខ្សែក្រវាត់លោតពណ៌មាស ។ ចំពោះនាយទាហានរង និងពលទាហាន អាវការងារពណ៌សកអាវទំលាក់មកក្រោមរាងជាកន្ទ្បែងវែងប្រវែង២៥ ស.ម ជុំវិញកអាវនេះមានឆ្នូត៣ ពណ៌ខៀវ ឆ្នូតនិមួយៗមានទំហំ៨ ស.ម ។ ហើយពាក់មួកម៉ាតឡូពណ៌សជើងមួកពណ៌ខៀវ លើជើងមួក សរសេរអក្សរពណ៌សថា (កងនាវាចរភូមិន្ទកម្ពុជា) កំពស់អក្សរ១៥ម.ម ។ ជើងមួកខាងក្រោយផែក មានខ្សែពីរសំរាប់ចងកន្ទុយខ្សែមានរាងកន្ទុយត្រី ។

-ចំពោះនាយទាហានត្រូវបានបន្ថែមឯកសណ្ឋានខ្មៅមួយសំរាប់ទៀតដែលមាន រូបភាព ម៉ូត អាវកាត់លំនាំអាវវ៉ារី កបើក គ្មានផែកខ្នង គ្មានប៉ូលស្មា មានហោប៉ៅចំនួន៣ ( ហោប៉ៅលើក្រោមដេរបង្កប់ ) ឡេវមានរូបព្រះគង្ហារ ពណ៌មាស ពីរជួរខាងមុខ៣ម្ខាង ។ នៅចុងដៃអាវមានដេរសញ្ញាសក្តិចម្ងាយ៦ស.ម ហួតពីចុងដៃអាវឡើងមកលើតាមឋានន្តរសក្តិ ។

-សក្តិដៃអាវថ្នាក់ឧត្តមនាវីលេចក្បាច់ផ្កាភ្ញី ៦ស.ម ពីចុងដៃអាវ ( ផ្កាភ្ញីមានទំហំ ១ស.ម ) ។ ផ្កាយថ្នាក់ឧត្តមនាវីពាក់លើផ្កាភ្ញីកំពស់ ១,២ ស.ម ហើយទាបតាមចំនួនផ្កាយចំហៀងខាងក្រៅនៃដៃអាវ ។

-អាវសឺមីពណ៌ស ក្រវាត់កពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

-មួកកាសស្កេតពណ៌ស តាមឋានន្តរសក្តិ ។

-ខោជើងវែងពណ៌ខ្មៅ ថ្នេរបង្កប់ ចង្កេះត មានភ្ជីពីរ ហោប៉ៅបួន ( ខាងក្រោយពីរគ្មានគំរប នៅចំហៀងដេរបញ្ចិតតាមថ្នេរខោ )

-ស្បែកជើងកខ្លីពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

-ឯកសណ្ឋានប្រយុទ្ធ ដូចទ័ពជើងគោក តែប៉េរ៉េពណ៌ខៀវទឹកសមុទ្រ ហើយកន្សែងរុំក (ហ្វូឡា) ពណ៌ខៀវទឹកសមុទ្រ ( ខៀវទឹកប៊ិច ) ។

ខ-<u>ឯកសណ្ឋានកងអាកាសចរភូមិន្ទ កម្ពុជា</u> :

គ្រប់ប្រភេទនៃឯកសណ្ឋាននិងគ្រប់បណ្តាថ្នាក់នាយទាហាន នាយទាហានរងនិង ពលទាហាន មានឯកសណ្ឋានដូចគ្នាជើងគោក តែឯកសណ្ឋានអាកាសចរភូមិន្ទកម្ពុជាត្រូវបានកំណត់ពណ៌ ដូចខាងក្រោម ៖

១-<u>ឯកសណ្ឋានលេខ ១</u> : អាវកុដស ពណ៌ស ខោពណ៌ខៀវក្រមៅនិងមួកកាសស្កេតពណ៌ខៀវក្រមៅជើងមួកពណ៌ក្រហម ។

២-<u>ឯកសណ្ឋានលេខ ២ លេខ ៣ និងលេខ ៤</u> : ពណ៌ខៀវក្រមៅ ស្បែកជើងពណ៌ខ្មៅដូចទ័ពជើងគោកដោយឡែកអាវសឺមីក្នុងរបស់ឯកសណ្ឋានធំលេខ ២កាត់ដូចជើងគោក ពណ៌ផ្ទៃមេឃ ។ ហើយ

ឯកសណ្ឋានការងារមានមួយសំរាប់ អាវពណ៌ខៀវផ្ទៃមេឃ ខោពណ៌ខៀវក្រមៅ មួកបេរ៉េពណ៌ខៀវក្រមៅកាត់ដូចទ័ពជើងគោកនិងខ្សែក្រវាត់តូចពណ៌ទឹកប៊ិច ក្បាលលាតពណ៌មាស ។

៣-ឯកសណ្ឋានប្រយុទ្ធ ៖ ដូចទ័ពជើងគោក ប៉េប៉េនិងកន្សែងរុំកពណ៌ខៀវ ( ខៀវផ្ទៃមេឃ ) ។

មាត្រា ៣ .- ក្នុងមាត្រា៣ថ្មីនៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រូវបានកែតម្រូវដូចខាងក្រោម ៖

ត្រូវបានរៀបចំឯកសណ្ឋានព្រៃទ័ពនិងកងកិត្តិយសដូចខាងក្រោម ៖

ក-ឯកសណ្ឋានព្រៃទ័ព ៖

-ឯកសណ្ឋានព្រៃទ័ពមានពីរសំរាប់ មួយពណ៌ស មួយទៀតពណ៌ត្រែអ៊ី ម៉ូត រូបភាពឯកសណ្ឋាននិងមួកកាសស្តេតដូចឯកសណ្ឋានលេខ ២ តែមួកកាសស្តេតធ្វើតាមឋានៈដូចទ័ពជើងគោក ស្បែកជើងស្បែក ករ៉េងពណ៌ខ្មៅ ខ្សែក្រវាត់ធំពណ៌ខ្មៅ ក្រវាត់ពីលើអាវ អាវសឺមីក្នុងពណ៌ត្រែអ៊ីខ្ចីមួយពណ៌សមួយ ខ្សែរយោលពណ៌មាសនិងកន្សែងរុំកពណ៌លឿង ស្រោមដៃពណ៌ស ។

ខ-ឯកសណ្ឋានកងកិត្តិយស ៖

១-ឯកសណ្ឋានមេបញ្ជាការកងកិត្តិយសនិងអ្នកកាន់ទង់ ៖ ត្រូវពាក់ឯកសណ្ឋានលេខ ២ របស់ទ័ពជើងគោកតាមឋានន្តរសក្តិជាក់ស្តែង ។ ចំពោះមេបញ្ជាការកងកិត្តិយសតាមបណ្តាផែន ជើង គោក នាវាចរ អាកាសចរ ត្រូវបានពាក់ឯកសណ្ឋានធំលេខ ២តាមឋានន្តរសក្តិជាក់ស្តែងនិងតាមប្រភេទ ទ័ព ។

២-ឯកសណ្ឋានកងកិត្តិយស ជើងគោក ៖ ឯកសណ្ឋានមានមួយសំរាប់ពណ៌ត្រែអ៊ីដូចព្រៃទ័ព តែខុសគ្នាកងកិត្តិយសជើងគោកពាក់មួកស៊ូកាសពណ៌ខ្មៅ កន្សែងរុំកពណ៌លឿង ។

៣-ឯកសណ្ឋានកងកិត្តិយស នាវាចរ ៖ ឯកសណ្ឋានពណ៌ស មួកស៊ូកាសពណ៌សនិងកន្សែងរុំកពណ៌ស ( កាត់ម៉ូតឯកសណ្ឋានលេខ ២ កងនាវាចរភូមិន្ទកម្ពុជា ) ។

៤-ឯកសណ្ឋានកងកិត្តិយស អាកាសចរ ៖ ឯកសណ្ឋានពណ៌ខៀវក្រមៅ មួកស៊ូកាសពណ៌ខៀវកន្សែងរុំកពណ៌ផ្ទៃមេឃ កាត់ដូចឯកសណ្ឋានលេខ ២ កងអាកាសចរភូមិន្ទកម្ពុជា ។

៥-ឯកសណ្ឋានកងកិត្តិយស ដាវ ៖ ពាក់ឯកសណ្ឋានលេខ ១ ថ្នាក់អនុសេនិយ ប្រើដាវមានស្រោមពណ៌សខ្សែរយោលដាវពណ៌មាស ដងដាវឆ្លាក់រូបព្រហ្មមុខបួន ផ្លែដាវពណ៌ទឹកប្រាក់ ចង្កូំនិងដងដាវក្បាច់ពណ៌មាស ។

មាត្រា ៤ .- ក្នុងមាត្រា ៤ថ្មី នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រូវបានកែតម្រូវដូចខាងក្រោម ៖

ត្រូវបានកំណត់អំពីរបៀបប្រើប្រាស់និងពាក់ឯកសណ្ឋាន ផ្លាកនានា នៃកងយោធពលខេមរភូមិន្ទ ដូចខាងក្រោម ៖

-ការស្លៀកពាក់ឯកសណ្ឋានគឺជាច្បាប់របស់កងយោធពលខេមរភូមិន្ទ ដែលនាយទាហាន នាយទាហានរង និងពលទាហានគ្រប់រូបត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់បំផុតមិនអាចខះបានឡើយ សំដៅធ្វើអោយយោធិន

គ្រប់រូបទូទាំងកងយោធពលខេមរភូមិន្ទបានឯកភាពគ្នា ។ ហើយការស្លៀកពាក់ឯកសណ្ឋានត្រូវអនុវត្តអោយបានត្រឹមត្រូវតាមការកំណត់នៃអនុក្រឹត្យនេះ មិនអនុញ្ញាតអោយយោធិនណាម្នាក់ស្លៀកពាក់ខុសពីការកំណត់ឡើយ ហើយការស្លៀកពាក់ឯកសណ្ឋានត្រូវពាក់សក្តិតាមឋានន្តរសក្តិរបស់ខ្លួន ព្រមទាំងផ្លាកសញ្ញា ផ្សេងៗដែលកងយោធពលខេមរភូមិន្ទបានកំណត់ ។

ការប្រើប្រាស់និងពាក់ឯកសណ្ឋាន ផ្លាកសញ្ញានានា :

១-<u>ឯកសណ្ឋានធំលេខ ១</u> : ( អាវកុដ ស )

-ឯកសណ្ឋានធំលេខ ១ សំរាប់ពាក់ក្នុងពិធីចូលព្រះបរមរាជវាំងនិងព្រះរាជពិធីដូចជា : ច្រត់ព្រះនង្គ័ល អុំទូក បុណ្យឯករាជ្យជាតិ ។ល ។

-ស្លៀកពាក់ឯកសណ្ឋានធំ អាវកុដស ខោពណ៌ក្រមៅ ឆ្នូតក្រហម មួកកាសស្កេតខ្មៅ មានរូបព្រះសង្ហារស្បែកជើងឃ្លុបស្បែក កខ្លីពណ៌ខ្មៅ ស្រោមជើងខ្មៅ ពាក់សក្តិលើស្មាដែលមានផ្ទៃហ្វូងសក្តិក្រណាត់កាំម៉ឺពណ៌មាស ពាក់ខ្សែរំយោលលើស្មាស្តាំ កន្ទុយខ្សែថ្កត់ឡេវអាវទី២ និងពាក់គ្រឿងឥស្សរិយយសនៅខាងឆ្វេង ( បើមាន ) ហើយស្រោមដៃតាមពិធីការកំណត់ ។ ចំពោះផ្លាកឈ្មោះ រូបហនុមាននិងសញ្ញាប្រភេទទ័ពនៅកអាវ ឬ សញ្ញាផ្សេងៗទៀតមិនត្រូវពាក់ជាមួយឯកសណ្ឋានធំលេខ ១ នេះឡើយ ។

-ចំពោះកងនាវាចរនិងអាកាសចរត្រូវពាក់ឯកសណ្ឋានធំលេខ១របស់ខ្លួន របៀបស្លៀកពាក់និងពាក់សំភារៈរួមផ្សំដូចទ័ពជើងគោកដែរ ។

២-<u>ឯកសណ្ឋានធំលេខ ២</u> : ( អាវវ៉ារី )

-ឯកសណ្ឋានធំលេខ ២ នេះពាក់សំរាប់ចូលរួមក្នុងពិធីការជាតិនិងអន្តរជាតិធំៗ ( តាមការកំណត់របស់ពិធីការ ) ព្រមទាំងការចេញទៅបំពេញបេសកកម្មក្រៅប្រទេស ។

-ស្លៀកពាក់ឯកសណ្ឋានធំលេខ ២ ពាក់អាវសឺមីពណ៌ត្រែអ៊ីខ្លីទាំងពេលថ្ងៃ យប់និងបុណ្យសពក្រវាត់កពណ៌ខ្មៅ ខោជើងវែងពណ៌ត្រែអ៊ី មួកកាសស្កេតពណ៌ត្រែអ៊ី មានរូបព្រះសង្ហារ ស្បែកជើងកខ្លីពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ពាក់សក្តិស្មា ផ្ទៃហ្វូងពណ៌ខ្មៅ ក្បាលស្រួច ពាក់ខ្សែរំយោលលើស្មាស្តាំ កន្ទុយខ្សែពាក់ឡេវអាវទី១ ពាក់សញ្ញានៅកអាវ ពាក់ផ្លាកឈ្មោះនៅលើហោប៉ៅអាវស្តាំ បន្ថោងរូបហនុមាននៅលើហោប៉ៅស្តាំ ពាក់ស្រោមដៃតាមពិធីការកំណត់និងគ្រឿងឥស្សរិយយសនៅខាងឆ្វេង ( លក្ខណៈចាំបាច់គួរពាក់មេដៃនិងលក្ខណៈធម្មតាពាក់ក្បាលមេដៃ ) ។ ចំពោះការចេញទៅបំពេញបេសកកម្មក្រៅប្រទេសមិនបាច់ពាក់ខ្សែរំយោលឡើយ ។

-ចំពោះកងនាវាចរនិងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានធំលេខ២ របស់ខ្លួននិងពាក់គ្រឿងរួមផ្សំផ្សេងទៀតព្រមទាំងរបៀបពាក់ដូចទ័ពជើងគោកដែរ តែកងនាវាចរត្រូវស្លៀកពាក់ឯកសណ្ឋានធំលេខ ២ ពណ៌ខ្មៅសំរាប់ពាក់ពេលបំពេញបេសកកម្មនៅក្រៅប្រទេសនារដូវរងារ ។ ឯកងអាកាសចរឆ័ត្រយោងត្រូវពាក់សញ្ញារបស់ខ្លួនលើផ្លាកឈ្មោះថែមទៀត ។ ការចេញទៅក្រៅប្រទេសមិនបានពាក់ខ្សែរំយោលឡើយ ។

-ចំពោះនៅដៃអាវមិនបានពាក់ផ្លាកកងយោធពលខេមរភូមិន្ទនិងផ្លាកអ្វីទៀតឡើយ ។

៣-<u>ឯកសណ្ឋានលេខ ៣</u> : ( សាហារីយែន )

-ឯកសណ្ឋាននេះពាក់សំរាប់ចូលក្នុងពិធីការជាតិនិងអន្តរជាតិដែលមានលក្ខណៈធម្មតា និងពិធីការយោធាផ្សេងៗដូចជា : ទទួលភ្ញៀវជាតិនិងអន្តរជាតិ ពិធីបិទវគ្គ បើកវគ្គ ។ ល ។

-<u>ការស្លៀកពាក់</u> : ពាក់អាវសាបារីយែន នៅដៃអាវស្តាំ ដាក់ផ្លាកកងយោធពលខេមរភូមិន្ទ ខោជើងវែង ពណ៌ព្រៃអ៊ី មួកកាសស្កេតពណ៌ព្រៃអ៊ី មានរូបព្រះសង្ហារ ស្បែកជើងស្បែក កខ្មី ពណ៌ខ្មៅ ពាក់សញ្ញាកពាក់សក្តិស្មាដែលមានផ្ទៃហ្វុងសក្តិពណ៌ខ្មៅ ក្បាលស្រួច ពាក់ផ្លាកឈ្មោះ សញ្ញាបានមុខមាននិងក្បាលមេដៃ ( បើមាន ) ។

-ចំពោះកងនាវាចរនិងអាកាសចរត្រូវស្លៀកពាក់ឯកសណ្ឋានលេខ ៣របស់ខ្លួន ហើយពាក់គ្រឿងរួមផ្សំផ្សេងទៀតនិងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរឆ័ត្រយោង ឬ កងឯកភាព ដែលមានផ្លាកសញ្ញាលើហោប៉ៅស្តាំលើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

៤-<u>ឯកសណ្ឋានលេខ ៤</u> : ( ឯកសណ្ឋានការងារ )

-ឯកសណ្ឋាននេះសំរាប់ពាក់ធ្វើការងារធម្មតាក្នុងការិយាល័យ ឬក្នុងបន្ទាយនិងទំនាក់ទំនងការងារធម្មតា ។

-<u>ការស្លៀកពាក់</u> : ពាក់អាវដៃខ្លីពណ៌ព្រៃអ៊ី នៅដៃអាវស្តាំដាក់ផ្លាកកងយោធពលខេមរភូមិន្ទ និងនៅដៃអាវឆ្វេងពាក់ផ្លាកកងឯកភាព ( បើមាន ) ខោជើងវែងពណ៌ព្រៃអ៊ី ខ្សែក្រវាត់ក្រួចពណ៌ព្រៃអ៊ី មួកបេរ៉េពណ៌ព្រៃអ៊ីមានរូបព្រះសង្ហារនៅខាងមុខផ្នែកខាងស្តាំនិងមានសញ្ញាសក្តិនៅខាងមុខផ្នែកខាងឆ្វេង ស្បែកជើងស្បែក កខ្មីពណ៌ខ្មៅនិងស្រោមជើងខ្មៅ ពាក់សញ្ញាប្រភេទទ័ពនៅកអាវ ផ្លាកឈ្មោះនៅលើហោប៉ៅស្តាំ បានមុខពាក់នៅឡែវហោប៉ៅស្តាំ សក្តិនៅលើស្មាដែលមានហ្វុងសក្តិខ្មៅ ក្បាលស្រួចនិងពាក់ក្បាលមេដៃ ( បើមាន ) អាវជានិច្ចកាលត្រូវដាក់ក្នុងខោ ។

-ចំពោះកងនាវាចរនិងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានការងារតាមការកំណត់ខាងលើ ហើយពាក់គ្រឿងរួមផ្សំផ្សេងទៀតនិងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរនិងបណ្តាកងឯកភាពដែលមានសញ្ញាលើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

៥-ឯកសណ្ឋានលេខ ៥ : ( ឯកសណ្ឋានប្រយុទ្ធ )

-ឯកសណ្ឋានប្រយុទ្ធនេះពាក់សំរាប់ចេញប្រតិបត្តិការឬបេសកកម្មក្រៅបន្ទាយ ចំពោះនៅក្នុងបន្ទាយអាចពាក់បាន តែត្រូវមានការកំណត់ពីមេបញ្ជាការហើយបានឯកភាពគ្នាទូទាំងកងឯកភាព ។

-<u>ការស្លៀកពាក់</u> : ពាក់អាវដៃវែង ហោប៉ៅបួន អាចមូរដៃបាន តែត្រូវឯកភាពគ្នា ( បើសិនជាមូរត្រូវមូរទាំងអស់គ្នា ) នៅលើដៃអាវស្តាំដាក់ផ្លាកកងយោធពលខេមរភូមិន្ទនិងលើដៃអាវឆ្វេងដាក់ផ្លាកកងឯកភាព (បើមាន) ខោជើងវែងមានហោប៉ៅក្រៅមួយ ជើងខោចងខ្សែ ពាក់មួកល្បើកពីមានរូបព្រះសង្ហារឬពាក់បេរ៉េដាក់រូបព្រះសង្ហារស្តាំទាញបត្អើតមកឆ្វេង នៅពេលចេញប្រតិបត្តិការសឹកអាចពាក់មួកដែក ( ចំពោះការពាក់មួកគ្រប់ប្រភេទត្រូវអនុវត្តតាមការកំណត់របស់កងឯកភាពនីមួយៗ បើសិនពាក់មួកណាត្រូវពាក់មួកនោះអោយបានឯកភាពគ្នាទាំងអស់ ហើយហាមស្លៀកពាក់ដោយគ្មានមួក ពាក់សក្តិប្រយុទ្ធកអាវខាងឆ្វេង នៅកអាវស្តាំពាក់ផ្លាកសញ្ញា

ប្រភេទទ័ពឬទ័ពជំនាញនៅកអាវ ( អាចប៉ាក់ផេរភ្ជាប់កអាវពណ៌មាស ) ផ្លាកឈ្មោះត្រូវដេរភ្ជាប់អាវលើហោប៉ៅស្តាំ អក្សរពណ៌ខ្មៅ ពាក់តន្ត្រីបរុក អាចមិនពាក់បានតាមការកំណត់របស់កងឯកភាព ពាក់សក់ងវៀន ( ខ្សែក្រវាត់ធំ ) និងពាក់ស្បែកជើងកវែងពណ៌ខ្មៅឬស្បែកជើងមែឮកកវែង ។

-ចំពោះកងអាកាសចរនិងកងនាវាចរពាក់ឯកសណ្ឋានប្រយុទ្ធរបស់ខ្លួន ហើយពាក់គ្រឿងរួមផ្សំនិងរបៀបប្រើប្រាស់ដូចទ័ពជើងគោក ។ តែកងអាកាសចរនិងបណ្តាកងឯកភាពដែលមានសញ្ញាលើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវប៉ាក់ភ្ជាប់អាវ រូបសញ្ញាពណ៌មាស ។

៦-<u>ឯកសណ្ឋានបច្ចេកទេសជំនាញ</u> :

-ការស្លៀកពាក់ឯកសណ្ឋានបច្ចេកទេសជំនាញដែលបានកំណត់ខាងលើ ចំពោះបណ្តាកងឯកភាពដែលមានឯកសណ្ឋាននេះត្រូវពាក់នៅពេលធ្វើការបច្ចេកទេសជាមួយគ្រឿងចក្រនិងឧបករណ៍បច្ចេកទេស ពេលចប់ត្រូវផ្លាស់ប្តូរវិញ មិនបានពាក់ឯកសណ្ឋាននេះដើរចេញក្រៅកងឯកភាពឬក្រៅម៉ោងធ្វើការបច្ចេកទេសឡើយ លើកលែងតែអ្នកបើកយន្តហោះ ។ ហើយឯកសណ្ឋាននេះមិនចាំបាច់ពាក់សក្តិ សញ្ញាផ្សេងៗរបស់កងយោធពលខេមរភូមិន្ទទេ ។ តែអ្នកបើកបរយន្តហោះត្រូវដាក់រាល់សញ្ញាដែលមាន ( ប៉ាក់ភ្ជាប់ ) និងសក្តិ ។

៧-ចំពោះទង់កងយោធពលខេមរភូមិន្ទគ្រប់បណ្តាថ្នាក់ត្រូវរក្សាទុកកន្លែងដែលមានសុវត្ថិភាពថ្លៃថ្នូរ និងការពារហើងមិតចត់បំផុត ។ ក្នុងរយៈពេលមួយឆមាសត្រូវប្រារព្ធពិធីសច្ចាប្រណិធានចំពោះមុខទង់របស់ខ្លួនម្តង ។ ពេលយកចេញមកក្រៅត្រូវធ្វើអោយបានត្រឹមត្រូវតាមភូមិបទយោធា ។

-នាយទាហាន នាយទាហានរងនិងពលទាហានទូទាំងកងយោធពលខេមរភូមិន្ទ ត្រូវស្លៀកពាក់ឯកសណ្ឋានតាមការកំណត់ខាងលើក្នុងអនុក្រឹត្យនេះ ។ ចំពោះបុគ្គលណាម្នាក់ដែលមិនបានស្លៀកពាក់អោយបានគ្រប់គ្រាន់តាមការកំណត់នេះត្រូវចាត់ទុកជាការល្មើសនឹងវិន័យរបស់កងយោធពលខេមរភូមិន្ទ ។

-ចំពោះការផលិតត្រូវធ្វើតាមការកំណត់របស់អនុក្រឹត្យនេះ និងមានគុណភាពខ្ពស់ ។

-ក្នុងករណីមានជំនួយពីបណ្តាប្រទេសជាមិត្ត អំពីឯកសណ្ឋានឬយោធបរិក្ខារផ្សេងៗ ហើយខុសពីការកំណត់នេះ អាចប្រើប្រាស់បានលុះត្រាតែមានការអនុញ្ញាតជាផ្លូវការពីក្រសួងការពារជាតិនិងអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ៥ .- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ .- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ស៊ីសុវត្ថិ សិរីរត្ន ទៀ បាញ់

* * *